ក-270

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយនិពន្ធខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ឃុនវិចិត្រទូមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកនិពន្ធសាសនាៈ លោកអាចារ្យ កៅ-ស៊ុំ អ្នកត្រួតត្រា សិស្សនៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង


| | | |
|---|---|---|
| **ផ្នែកអក្សរសាស្ត្រ** | | ទំព័រ |
| លោកអាចារ្យ កៅ-ស៊ុំ . . . . . | វិទ្យុតម្ពទេសនា កណ្ឌទី ១៥ . . . . . . . . | ១ |
| លោកអាចារ្យ ឈឹម-ស៊ុំ . . . . . | " " ១៦ . . . . . . . . | ១៤ |
| ព្រះមហា សោម-ឡុច . . . . . | " " ១៧ . . . . . . . . | ២៩ |
| លោក សង់-ហង់វីបហុប . . . . | អំពីសេចក្ដីជីវិតនៃសត្វល្អិត . . . . . . . . | ៣៦ |
| អ្នកនិពន្ធកាព្យរឿងព្រហ្មវិនិច្ឆ័យ កែវ-ហង្ស | ប្រលោមចិត្ត (ពាក្យកាព្យ) . . . . . . . . | ៥៨ |
| អ្នកនិពន្ធរឿងភោគសាធ (ង៉ង) . . | លោកនេយ្យ ពាក្យកាព្យ (តមក) . . . . | ៧៩ |
| ឃុនវិចិត្រទូមន្ត្រី ញ៉ុក-ថែម . . . . . | ពង្សាវតារប្រទេសចិន . . . . . . . . . . | ១០៥ |
| **ផ្នែក..សនា** | | |
| អណាំងអំពីក្រសួងការ . . . . | បញ្ជីរាយនាមមន្ត្រីសង្ឃនឹងលោកអធិការ ដែល ទើបតាំងឡើងថ្មី . . . . . . . . . . . . . | ១២៤ |
| " " . . . . . . | បុណ្យបញ្ចុះសីមានៅវត្តនាគ . . . . . . . | ១២៩ |
| ឃុនវិចិត្រទូមន្ត្រី ញ៉ុក-ថែម . . . . | ប្រវត្តិសង្ខេបបញ្ញមសង្ឃនាយក(តមកនឹងចប់). | ១៣៧ |
| " " . . . . . . | ប្រវត្តិព្រះមហាកញ្ចាយនត្ថេរ . . . . . . . . | ១៣៦ |
| [illegible]ចារ្យ ឈឹម-ស៊ុំ . . . . | ពុទ្ធឃោសប្បវត្តិ . . . . . . . . . . . . | ១៤៣ |


[illegible]ទី ៥ លេខ ១-២-៣ ប្រចាំខែ យ៉ាំងវីយេរ- ហ្វេវ្រីយេរ- ម៉ារ្ស ១៩៤៣ ។

ដំឡៃផ្សារ ១ ច្បាប់ ១០:០០ ។

វិទ្យុជម្ពូទេសនាកាណ្ឌទី ១៧

ព្រះមហាសោម-ឡុប ក្រុមជំនុំព្រះត្រៃបិដក

សំដែងនៅថ្ងៃសៅរ៍ ១៥ កើតខែអាសាឍ ឆ្នាំរោងចត្វាស័ក ពុទ្ធសករាជ ២៤៩៥

( ២៨ យូវិង ១៩៥២ )

# វិបត្តិកថា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

លំដាប់អំពីនមស្សការមក សូមស្រង់លើកយកវិបត្តិ ៦ ប្រការ ដែលព្រះបរមសាស្តាចារ្យទ្រង់សំដែងទុក ដើម្បីនឹងផ្សាយចែកជូនដល់អស់លោកអ្នកសប្បុរសទាំងឡាយ បានជ្រាប ។

ក៏ពាក្យដែលហៅថា វិបត្តិៗ នេះ ប្រែថាវិនាសទៅ ថាប្រែប្រួលទៅមិនបានគង់នឹងនៅដូចធម្មតា គឺថារបស់ណាធ្លាប់មាន ត្រឡប់ទៅជាគ្មាន ធ្លាប់សុខត្រឡប់ទៅជាទុក្ខ ធ្លាប់ធំត្រឡប់ទៅជាតូច ធ្លាប់ខ្ពស់ត្រឡប់ទៅជាទាប ប៉ុណ្ណេះជាដើមហៅថាវិបត្តិ ។

ឯវិបត្តិទាំង ៦ ប្រការនោះគឺ គតិវិបត្តិ វិបត្តិគតិ ១ កាលវិបត្តិ វិបត្តិពេលវេលា ១ ទេសវិបត្តិ វិបត្តិស្រុកទេស ១ កុលវិបត្តិ វិបត្តិត្រកូល ១ ឧបធិវិបត្តិ វិបត្តិរាងកាយ ១ ទិដ្ឋិវិបត្តិ វិបត្តិទិដ្ឋិ ១ ។

ត្រង់គតិវិបត្តិទី ១ សេចក្តីអធិប្បាយថា បុរសបុគ្គលក្នុងលោកនេះ កម្រមានគតិគឺដំណើរដែលនឹងធ្វើមរណកាលទៅវិញឲ្យបានទីស្ថានសុខ

ស្រួលពេកណាស់ ច្រើនវិបត្តិប្រែប្រួលអត្តភាពពីកាយក្លាយទៅកើតក្នុងអបាយភូមិ ៤ គឺនរក ប្រេត អសុរកាយ តិរច្ឆាន គ្រប់ជាតិនានា ។

ចំណែកខាងនរក ប្រេត អសុរកាយ ទាំង ៣ អស់លោក-អ្នកទាំង-ឡាយគ្រាន់តែបានឮតៗមក មិនដែលបានឃើញជាក់ច្បាស់ដោយនេត្រា ម្ល៉ោះហើយជនខ្លះក៏មានវិចិកិច្ឆា សន្ទេះសង្ស័យក្នុងចិត្ត ព្រោះគិតមិនស្រ-ឡះ មានជនបំពួកខ្លះក៏លែងជឿដោយដាច់ខាត ដោយផ្ទៃចិត្តចុះស៊ប់ក្នុងសេចក្ដីប្រមាថជាដើមហេតុ បានជាប្រកាន់ថាគ្មាន នរក ប្រេត អសុរ-កាយ នេះព្រោះចំហាយមោហ មកបិទបាំងបញ្ញា បើនឹងពោលដោយពិតតាមគម្ពីរបិដកព្រះពុទ្ធសាសនា ព្រះពុទ្ធដីកាទ្រង់សំដែងថាប្រាកដជាមាន លុះតែជនណាមានញាណដូចព្រះអរហន្តមិនកាន់ច្រឡំទើបអាចឃើញពួកអទិស្សមានកាយទាំងនោះបាន ឯសត្វដែលទៅកើតក្នុងអបាយទាំងប៉ុន្មាន ក៏ឥតបានសប្បាយបន្តិចបន្តួចសោះ មានតែសេចក្ដីទុក្ខមកគ្របសង្កត់សព្វពេលវេលា មិនឈ្នះនឹងពណ៌នាឲ្យពិស្ដារបាន ។

វេលានេះ សូមលើកយកតែពួកតិរច្ឆានមកសំដែង ព្រោះសត្វទាំងនោះឯង អស់លោក-អ្នកធ្លាប់បានឃើញច្បាស់ដោយចក្ខុគ្រប់គ្នា ឯសត្វតិរច្ឆានទាំងនោះគឺ ឆ្កែ, ឆ្មា, មាន់, ទា, ជ្រូក, គោ, ក្របី, ដំរី, សេះ, ប៉ុណ្ណោះជាដើម ជាសត្វថោកទាបបំផុត មិនស្គាល់ខុសត្រូវគុណទោស បុណ្យបាបអ្វីឡើយ ហើយទាំងមិនមានចេតនាជ្រះថ្លាក្នុងព្រះពុទ្ធព្រះធម៌ ព្រះ

សង្ឃ និងមានសីលភាវនា ទាំងចំណេះវិជ្ជាផ្លូវលោកផ្លូវធម៌ក៏ឥតបានចេះ ដឹងបន្តិចបន្តួច ចំណែកខាងឯនាមឈ្មោះក៏បាត់ពីកេះពិសា សព្វថ្ងៃនេះ មនុស្សលោកច្រើនហៅមី ហៅអា ជេរប្រទេចផ្ដាសាតាមទំនើងចិត្តឥត មានខ្លាច នេះដោយអំណាចអំពើទុច្ចរិត ដែលខ្លួនប្រព្រឹត្តធ្វើពីឥឡូវឬពី ជាតិមុនមកទាំងប៉ុន្មាន ទើបផលកម្មនោះដឹកនាំឲ្យកើតជាតិរច្ឆាន កម្រ នឹងបានរួចមកកើតជាមនុស្សវិញឡើយ នេះឯងហើយហៅថាគតិវិបត្តិ ។

ត្រង់កាលវិបត្តិទី២សេចក្ដីអធិប្បាយថា កាលវិបត្តិពេលវេលា ពេលវេលាណាមានព្រះពុទ្ធត្រាស់ក្នុងលោក សំដែងធម៌ទេសនាប្រោសពួក ពុទ្ធបរិស័ទនានា ជនទាំងនោះក៏កើតសទ្ធាជ្រះថ្លាបានសម្រេចមគ្គផលពុំ អាចនឹងពណ៌នាបាន ចំណែកពួកជនដែលឥតកំព្ង ឥតសំណាងទាំងប៉ុន្មាន ក៏អាក់ខានមិនបានកើតទាន់ពេលវេលា ដែលព្រះពុទ្ធត្រាស់នោះឡើយ ត្រឡប់ទៅកើតក្នុងអបាយភូមិ ឬក៏កើតក្នុងសុញ្ញកាលទៅវិញ គឺកាល ដ៏សូន្យ គ្មានព្រះពុទ្ធ បច្ចេកពុទ្ធ ស្ដេចចក្រ ពួកមនុស្សក្នុងពេលនោះ លោកហៅថាកាលវិបត្តិ ។ ពុំនោះសោតទេ ដូចកាលពីដើមមុន ៤០ ឆ្នាំ មកក្នុងកម្ពុជរដ្ឋយើងនេះ មិនសូវមានលោកអ្នកប្រាជ្ញណាចេះដឹងខាងផ្លូវ ព្រះពុទ្ធសាសនានឹងពន្យល់ធម៌អាថ៌សិក្ខាវិន័យ ទាំងចំណេះវិជ្ជាទំនើបថ្មី ក៏ពុំសូវមាន ម្ល៉ោះហើយមនុស្សក្នុងពេលនោះ ច្រើនខ្សត់ខ្សោយចំណេះ វិជ្ជា បើនឹងចាត់តាមពេលវេលា ក៏ហៅថាវិបត្តិមួយដែរ តែឥឡូវកផការ

បានទំនុកបំរុងរៀបចំគ្រប់នាទីដំណែងឲ្យបានរៀបរយ មិនឲ្យមានភៀងឃ្លាត ពួកខេមរជាតិក៏កាន់តែបានបេះដូងច្រើនគ្នា ជនអ្នកមានភ័ព្វមានសំណាង កើតមកច្រើនបានជួបប្រទះនឹងពេលវេលាល្អ ជនណាដែលគ្មានភ័ព្វគ្មានសំណាងទេ ជននោះច្រើនកើតមកជួបប្រទះនឹងពេលវេលាមិនល្អ ដូចបានថ្លែងរៀបរាប់មកពីខាងដើមមិនសូវបានសេចក្ដីសុខសេចក្ដីចំរើនឡើយ នេះហើយហៅថាកាលវិបត្តិ ។

ត្រង់ទេសវិបត្តិទី ៣ នោះ សេចក្ដីអធិប្បាយថា ស្រុកទេសណាដែលសូន្យចាកព្រះពុទ្ធសាសនាគឺគ្មានធម៌អាថ៌សិក្ខាវិន័យ ទាំងគ្មានច្បាប់សម្រាប់ផែនដី ដើម្បីនឹងបំភ្លឺជនទាំងពួងឲ្យបានបេះដូងសេចក្ដីខុសត្រូវ ស្រុកទេសនោះៗហៅថាទេសវិបត្តិ ។

ពុំនោះសោតទេ ស្រុកទេសនោះៗមានព្រះពុទ្ធសាសនា បរិបូណ៌ត្រឹមត្រូវជាផ្លូវល្អមឲ្យអ្នកផងប្រតិបត្តិមិនឲ្យលំអៀងឃ្លៀងឃ្លាតទាំងច្បាប់សម្រាប់គ្រប់ប្រទេសជាតិ ក៏មានគ្រប់គ្រាន់ទាំងអស់ ប៉ុន្តែមកមានទំនាស់ដោយសេចក្ដីអន្តរាយគឺកើតចំបាំងកំពង់ផល់ឬកើតទុរ្ភិក្សអត់បាយ ប្រជា-ជនទាំងឡាយធ្វើស្រែចំការក៏ពុំសូវបានផលបរិបូណ៌ ចំណែកខាងពួកអ្នកធ្វើជំនួញជួញលក់ដូរក៏ច្រើនតែខាតមិនចំណេញ បើទុកណាជាទំរេកធនធានបានតិចច្រើន ក៏លំបាកព្រួយចិត្តនឹងថែទាំរក្សាគ្រប់ពេលវេលាជួនកាលពួកចោរវក់នាំគ្នាមកលួច ប្លន់ ឆក់ ប្រវ័ញ្ចដណ្ដើមយកឥតមាន

កំណត់ បើនឹងនិយាយឲ្យឃើញជាក់ច្បាស់ប្រាកដដូចកម្ពុជរដ្ឋប្រទេស យើងនេះពីដើមមក អ្នកក្រុង អ្នកចំការ អ្នកស្រែ ច្រើនត្អូញត្អែរពីរឿង ចោរលួច ចោរប្លន់ ពួករាស្ត្រទាំងប្រុសស្រីកើតទុក្ខព្រួយចិត្តគ្រប់ពេល វេលា ដោយសាររាជការជួយការពារ ទើបរាស្ត្ររាល់គ្នាបានសេចក្តី សុខស្រួល ។

ពុំនោះសោត ស្រុកទេសនោះៗ ពីដើមធ្លាប់បានសេចក្តីសុខសប្បាយ ថ្កុំថ្កើងរុងរឿងហ៊ឹកហ៊ាក់ លុះដល់គ្រាក្រោយមកទទួលគ្រោះថ្នាក់ដោយ សត្រូវមកបៀតបៀនធ្វើឲ្យវិនាសអន្តរាយ ដរាបពាល់តែក្លាយទៅជាស្រុក ដុនដាបរងទុក្ខវេទនាក្រៃលែង ដូចដែលកើតមកជួបប្រទះនឹងសម័យ ស្រុកទេសបែបនោះឯង ក៏រមែងបានសេចក្តីលំបាកវេទនាកម្រនឹងបាន ស្រាកស្រាន្តឡើយ នោះឯងហើយហៅថាទេសវិបត្តិ ។

ត្រង់កុលវិបត្តិទី ៤ សេចក្តីអធិប្បាយថា វិបត្តិត្រកូលក្នុងគ្រាពុទ្ធ-សម័យលោកចែកត្រកូលទាំងនោះទៅជា ៤ យ៉ាងគឺខត្តិយកុល ត្រកូល ក្សត្រិយ៍ ១ ព្រាហ្មណកុល ត្រកូលព្រាហ្មណ៍ ១ វេស្សកុល ត្រកូលអ្នក ធ្វើស្រែចំការនិងការលក់ដូរ ១ សុទ្ទកុល ត្រកូលស៊ីឈ្នួល ១ ។

បណ្តាត្រកូលទាំង៤នោះ ត្រកូលក្សត្រិយ៍ និងត្រកូលព្រាហ្មណ៍ គាត់ថាជាត្រកូលខ្ពង់ខ្ពស់ប្រសើរ ឯជាតិព្រាហ្មណ៍នោះមិនសូវជឿព្រះ ពុទ្ធសាសនាទេ ច្រើនជឿតែលទ្ធិក្រៅព្រះពុទ្ធសាសនា ដូចសាសនា

ព្រហ្មជាដើម ព្រាហ្មណ៍ចូលចិត្តជាបំផុតដោយយល់ថាព្រហ្មជាបង្កើតដី ទឹក ភ្លើង ខ្យល់ ឲ្យសព្វសត្វអាស្រ័យនៅបាន ហើយទាំងបានប្រកាន់ថា ជាតិព្រាហ្មណ៍ទាំងប៉ុន្មានសុទ្ធតែកើតមកពីព្រះឱស្ឋព្រហ្ម ជាតិក្សត្រិយ៍ កើតមកពីទ្រូងព្រហ្ម ជាតិវេស្សអ្នកស្រែចំការកើតមកពីស្នងជើងព្រហ្ម ជាតិសុទ្ទអ្នកស៊ីឈ្នួលកើតមកពីខ្នងជើងព្រហ្ម ជាតិសមណៈអ្នកបួសកើតមកពីបាទជើងព្រហ្ម ព្រោះហេតុនោះ បានជាពួកព្រាហ្មណ៍ច្រើន គោរពកប់គានព្រហ្មជាងព្រះ ។

ចំណែកខាងត្រកូលដែលថោកទាបជាងគេបំផុតនោះគឺ ត្រកូលសុទ្ទអ្នកស៊ីឈ្នួល សង្គ្រោះយកទាំងត្រកូលចណ្ឌាល ត្រកូលបុក្កុសៈអ្នកបោសសម្រាមប៉ុណ្ណោះជាដើម ចាត់ថាថោកទាបដូចគ្នា ថោកទាបទាំងពួកពាមារយាទទាំងផេតជើងឈើរអគ្គិយឧបាយស្តីគ្រប់យ៉ាង ហើយច្រើនខ្សត់ខ្សោយទ្រព្យសម្បត្តិមិនសូវបានបរិបូណ៌គ្រប់គ្រាន់ ទាំងមិនសូវមានគេកប់គានជាមុខជាមាត់ឡើយ នេះហើយហៅថា កុលវិបត្តិ ។

ត្រង់ឧបធិវិបត្តិទី ៥ សេចក្តីអធិប្បាយថា ជនពួកខ្លះក្នុងលោកនេះមានរូបកាយមិនបរិបូណ៌ ច្រើនតែវិបត្តិខ្លះខាតកាយឥន្ទ្រិយ មិនពេញជាប្រុសជាស្រីកើតកែលវិការៈផ្សេងៗ ខ្លះទៅជាមនុស្សខ្វើយ មនុស្សក្រេទពីរ មនុស្សគ ថ្លង់ ខ្វាក់ ខ្វិន ក្ងើកក្ងង់ កំពកកំពក ក្រញូក្រពិត គក្រក់លាមកដូចគាដូក ខ្លះកើតឃ្លង់ ស្រែង ហឺតរបេង កំបុតជើង

កំបុតដៃ កំបុតស្លឹកត្រចៀក កំបុតច្រមុះ ប៉ុណ្ណោះជាដើម មនុស្សបែបនេះលោកហៅថា បរិសទូសកៈ មនុស្សទ្រុស្តបរិស័ទ គឺគ្មានបរិស័ទណាចូលចិត្តស្រឡាញ់រាប់អានឡើយ នេះហើយហៅថាឧបធិវិបត្តិ ។

ត្រង់ទិដ្ឋិវិបត្តិទី ៦ សេចក្ដីអធិប្បាយថា ជនចំពួកខ្លះក្នុងលោកនេះ ច្រើនប្រើគំនិតដែលខុសផ្លូវមិនត្រូវតាមទំនងព្រះពុទ្ធដីកាបានជាតឹង ៗ ពេក ធូរៗ ពេក ឆ្វេងៗ ពេក ស្ដាំៗ ពេក ឥតបានត្រូវលើផ្លូវល្អត្រង់ណា ទិដ្ឋិនេះបើចាត់ចែកតាមបទមាតិកាលោកប្រាប់ថាមានអដ្ឋ ៨ គឺ មិច្ឆា-ទិដ្ឋិ ១ មិច្ឆាសង្កប្បោ ១ មិច្ឆាវាចា ១ មិច្ឆាកម្មន្តោ ១ មិច្ឆាអាជីវោ ១ មិច្ឆាវាយាមោ ១ មិច្ឆាសតិ ១ មិច្ឆាសមាធិ ១ ។

សេចក្ដីថា កាលបើគំនិតយល់ខុសហើយ ត្រិះរិះក៏ខុស កាលបើត្រិះ-រិះខុសហើយ និយាយក៏ខុស កាលបើនិយាយខុសហើយ ធ្វើអំពើអ្វីក៏ខុស កាលបើធ្វើអំពើអ្វីខុសហើយ ចិញ្ចឹមជីវិតក៏ខុស កាលបើចិញ្ចឹមជីវិតខុសហើយ ព្យាយាមក៏ខុស កាលបើព្យាយាមខុសហើយ សតិក៏ខុស កាលបើសតិខុសហើយ សមាធិ ការដំកល់ចិត្តឲ្យនឹងនៅក្នុងអារម្មណ៍នោះៗ ក៏ខុសទៀត សេចក្ដីដូចបានរៀបរាប់មកប៉ុណ្ណោះជាដើម ហៅថាទិដ្ឋិវិបត្តិ ។

សំដែងមកអំពីរឿងវិបត្តិទាំង ៦ ប្រការ ក៏សន្និដ្ឋាបប់ដោយសង្ខេប, សូមឲ្យព្រះពុទ្ធសាសនាទាំងពុទ្ធបរិសទ្យអ្នកស្ដាប់ធម៌បានសេចក្ដីចំរើនសុខៗ កាលរៀងទៅ ងរំ សមគួរតាមវេលាប៉ុណ្ណោះឯង ។